**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
*********

# កិច្ចព្រមព្រៀង
## រវាង
## សិប្បកម្មប៉ាក់ ខុនហ្វីឌែន អ៊ីមប្រ៉យឌើរី ជាមួយ
## ប្រតិភូបុគ្គលិក និងតំណាងកម្មករនិយោជិត

នៅថ្ងៃទី.២៨ខែ.ធ្នូ.ឆ្នាំ២០២២ វេលាម៉ោង.៩ព្រឹក.និង...៣០.នាទី នៅក្នុង
បរិវេនារោងចក្រ

មានកិច្ចប្រជុំមួយរវាងតំណាងរោងចក្រ ប៉ាក់ ខុនហ្វីឌែន អ៊ីមប្រ៉យឌើរី នឹងតំណាងកម្មករ និយោជិក។

នៅក្នុងអង្គប្រជុំនេះ នាយករោងចក្របានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ន ក្រុមហ៊ុនខ្វះការបញ្ជាទិញរយះពេលវែង ដែលបណ្តាលអោយច្រវ៉ាក់ផលិតកម្មត្រូវផ្អាកដំណើរការ។ ហេតុដូចនេះ ក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៧នាក់ (ស្រី ៨នាក់) ក្នុងចំណោមកម្មករនិយោជិតសរុប ២០ (ស្រី ១៣នាក់) (ក្នុងប្រព័ន្ធព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតមានចំនួន ២៨នាក់ (ស្រី ១៦ នាក់) ហើយក្នុងចំណោមកម្មករនិយោជិត ២៨នាក់ កម្មករនិយោជិតដែលបានលាឈប់ពី ក្រុមហ៊ុនចំនួន ៨ នាក់ (ស្រី ៣នាក់) ) រយះពេល៦០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ២ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី ១ ខែមិនា ឆ្នាំ ២០២៣។ ហើយក្នុងកំឡុងពេលព្យួរការងារនេះ កម្មករនិយោជិកបានឯកភាពទទួលការផ្តល់ជូនរបស់រោងចក្រនូវប្រាក់ឈ្នួល ២៥%នៃប្រាក់ឈ្នួលប្រចាំថ្ងៃ ដោយរាប់បញ្ចូលប្រាក់ថ្លៃធ្វើដំណើរ៧ដុល្លានៅក្នុងហ្នឹងតែម្តង។

ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងានេះ និងបើកជូនបងប្អូនកម្មករ នៅថ្ងៃទី ២ ខែ មករា ឆ្នាំ ២០២៣។

អង្គប្រជុំបានចប់នៅវេលាម៉ោង..១០..និង៣០..នាទី ព្រឹកនាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោបល់សហការគ្នាយ៉ាងរលូន។

ថ្ងៃពុធ ៦កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦
រាជធានី ភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២
តំណាងរោងចក្រ

ស្នាមមេដៃតំណាងកម្មករ និយោជិក

Scanned with CamScanner